ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ: ៥៣៣ "ក្រ.វ"
-ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៣១
ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២
-ស៊ើបសួរលេខ៥២៣
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២
-ជំនុំជម្រះលេខ២០៦៣
ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង០០ នាទីព្រឹក នៅសាលសវនាការ ដោយមានសមាសភាព៖

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោកស្រី [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

តំណាងអយ្យការ
-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ
-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៣១ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted]**រ៉ាំងតេវ** ភេទប្រុស **អាយុ** ៤៧ឆ្នាំ ជនជាតិវៀតណាម មុខរបរ **ជាងដែក** ទីកន្លែងកំណើត នៅប្រ[redacted] ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ភូមិឡោតជ្រុំ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted]**រ៉ាំងសឹង្ហ** "រស់" ម្តាយឈ្មោះ [redacted] **អៀង** "ស្លាប់" ជាទីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៨៧៨** "ក១" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ។ (PJ)

២-ឈ្មោះ [redacted] **ហ្វឿងថាញ់** ភេទប្រុស **អាយុ** ៤៨ឆ្នាំ ជនជាតិវៀតណាម មុខរបរ **ជាងឈើ** ទីកន្លែងកំណើត[redacted] ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ភូមិឡោតជ្រុំ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] **ហ្វឿងវី** "រស់" ម្តាយ **មិនស្គាល់ឈ្មោះ** ជាទីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ **៨៧៩** "ក១" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ។ (PJ)

ជាប់ចោទពីបទ **ល្មួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

មេធាវី [redacted]

អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រីវិន** ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវលេខ១០BT ភូមិសន្សំកុសលទី៤ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អត្ថហេតុនៃរឿងមានដូចតទៅ

-កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៤ និង ១០នាទី នៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ មានករណី **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** មួយបានកើតឡើង បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] **ហ្សឿងថាញ់** ភេទប្រុស អាយុ ៤៨ឆ្នាំ ឈ្មោះ [redacted] **វ៉ាំងតេវ** ភេទប្រុស អាយុ ៤៧ឆ្នាំ និងឈ្មោះ **ម៉ៅ** ភេទប្រុស អាយុប្រហែល ៣៥ឆ្នាំ ។ នៅថ្ងៃកើតហេតុជនសង្ស័យខាងលើបានធ្វើសកម្មភាពឆក់ទូរស័ព្ទម៉ាក iPhone 13 Pro Max ពណ៌ខៀវ ពីដៃជនរងគ្រោះឈ្មោះ [redacted] **ស្រីវិន** ភេទស្រី អាយុ ២៤ឆ្នាំ ដែលកំពុងជិះផាស់អាប់ នៅចំណុចកើតហេតុខាងលើបានសម្រេចហើយជិះរត់គេចខ្លួនបាត់ ។ រហូតដល់វេលាម៉ោង ១៧ និង ០០ នាទី ជនរងគ្រោះបានឆែកឃើញទូរស័ព្ទដៃរបស់ខ្លួនតាម GPS ឃើញនៅចំណុចជិតផ្សារបឹងទំពុន ផ្លូវពពាបេតេ ភូមិសន្សំកុសលទី៣ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ភ្លាមនោះជនរងគ្រោះបានរាយការណ៍មកសមត្ថកិច្ចចុះទៅធ្វើការឃាត់ខ្លួនបានជនសង្ស័យឈ្មោះ [redacted] **ហ្សឿងថាញ់** និងឈ្មោះ [redacted] **វ៉ាំងតេវ** រួមនឹងវត្ថុតាងទូរស័ព្ទដៃ ០១គ្រឿងរបស់ជនរងគ្រោះ បញ្ជូនមកកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលខណ្ឌបឹងកេងកងទី១ ដើម្បីចាត់ការតាមនីតិវិធី ចំណែកជនសង្ស័យឈ្មោះ [redacted] ភេទប្រុស រត់គេចខ្លួនបាត់ ។

-**បានឃើញ**៖របាយការណ៍សំយោគលេខ ០០៣/**២២** រ.ប.ក ចុះថ្ងៃទី**២៩** ខែមករា ឆ្នាំ**២០២២** របស់អធិការដ្ឋាននគរបាលខណ្ឌបឹងកេងកង ។

-**បានឃើញ**៖ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **៤១៦ អ.ឃ.ញ** ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ**២០២២** របស់**អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ។

-**បានឃើញ**៖ដីកាសន្និដ្ឋានស្តាពរលេខ **១៨៣៩ អ.ឃ.ញ** ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ**២០២២** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ**៖ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **២៤៦៩** “**ក**” **ដ.ដ** ចុះថ្ងៃទី**២៣** ខែឧសភា ឆ្នាំ**២០២២** របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ដំណើរសវនាការ

-អំណាងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រីវិន** បានឆ្លើយថា៖ នៅមុនពេលកើតហេតុថ្ងៃទី**២៩** ខែមករា ឆ្នាំ**២០២២** វេលាម៉ោង ១១ និង ០០ នាទី ខ្ញុំ និងប្អូនស្រីបានជិះផាស់អាប់ ចេញពីផ្ទះនៅមុំវត្តសន្សំកុសល សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មកធនាគារ ABA ផ្លូវព្រះសីហនុ កែងនឹងផ្លូវលេខ

៦៣ សង្កាត់បឹងកេងកងទី១ ដើម្បីបង្កើតគណនេយ្យថ្មី នៅពេលខ្ញុំបានបង្កើតគណនេយ្យថ្មីរួច ខ្ញុំ និងប្អូនស្រីបាននាំគ្នាជិះផាស់អាប់ត្រឡប់ទៅផ្ទះជួលវិញ តាមបណ្តោយផ្លូវលេខ៦៣ ទៅត្បូងនៅពេលកំពុងជិះផាស់អាប់ ខ្ញុំបានយកទូរស័ព្ទដៃម៉ាក iPhone 13 Pro Max មកចុចផ្ញើសារទៅមិត្តភក្តិ ពេលជិះដល់កន្លែងកើតហេតុខាងលើស្រាប់តែមានជនសង្ស័យជិះម៉ូតូមកអែបខាងស្តាំដៃខ្ញុំ រួចធ្វើសកម្មភាពឆក់ទូរស័ព្ទដៃបានសម្រេច ហើយគេចខ្លួនបានសម្រេចតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted]**រ៉ាំងតេវ** បានឆ្លើយថា: ខ្ញុំសុំបញ្ជាក់ថាឈ្មោះ [redacted] **ហ្សឿងថាញ់** បានស្លាប់នៅក្នុងពន្ធនាគារហើយ ។ ម្តាយខ្ញុំមានឈ្មោះ [redacted]**អៀង** ។ ខ្ញុំបានស្តាប់អង្គហេតុដែលតំណាងអយ្យការបានចោទប្រកាន់ហើយ ។ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ខ្ញុំទើបតែប្រព្រឹត្តអំពើនេះម្តងទេ ហើយខ្ញុំធ្វើសកម្មភាពឆក់ទូរស័ព្ទគេពីផាស់អាប់ តែម្នាក់ឯងទេ ហើយឆក់បានសម្រេច ។ ក្រោយមកខ្ញុំបានហៅឈ្មោះ [redacted] **ហ្សឿងថាញ់** ជិះម៉ូតូជូនខ្ញុំទៅលក់ទូរស័ព្ទក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ហ្សឿងថាញ់** បានឆ្លើយនៅសមត្ថកិច្ចថា: នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ខ្ញុំកំពុងនៅផ្ទះជួលម្តុំភូមិត្នោតជ្រុំ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឈ្មោះ [redacted]**រ៉ាំងតេវ** ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិវៀតណាម ជិះម៉ូតូមួយគ្រឿងម៉ាកសង់ សេ១២៥ ពណ៌ខ្មៅ មិនមានអាវ និងស្លាកលេខ ក៏បបួលខ្ញុំយកទូរស័ព្ទទៅលក់នៅម្តុំផ្សារបឹងទំពុន ជិតវត្តសន្សំកុសល ។ នៅពេលខ្ញុំ និងឈ្មោះ [redacted]**រ៉ាំងតេវ** មកដល់ផ្សារបឹងទំពុន កំពុងតែឈរលក់ទូរស័ព្ទដៃក៏ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនរួមទាំងវត្ថុតាងតែម្តង ។

-សាក្សីសមត្ថកិច្ចឈ្មោះ [redacted] **គីមហេង** បានឆ្លើយថា: នៅថ្ងៃកើតហេតុសមត្ថកិច្ចបានទទួលពាក្យបណ្តឹងរបស់ជនរងគ្រោះដោយជនរងគ្រោះបានបញ្ជាក់ថាគាត់បានជិះម៉ូតូផាស់អាប់ ហើយបានយកទូរស័ព្ទតេរកមិត្តភក្តិរបស់គាត់ស្រាប់តែជនជាប់ចោទបានជិះម៉ូតូតាមក្រោយក៏បានឆក់ទូរស័ព្ទរបស់ជនរងគ្រោះបានសម្រេច ។ ក្រោយពេលបានទទួលពាក្យបណ្តឹងសមត្ថកិច្ចបានស្រាវជ្រាវតាម GPS ក៏ចាប់ខ្លួនជនជាប់ចោទនៅម្តុំបឹងទំពុន ក៏បានយកមកធ្វើការសាកសួរ ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ: ក្រោយពីបានពិនិត្យសំណុំរឿង និងស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថាជនចាប់ចោទពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច ពិតមែន ។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]**រ៉ាំងតេវ** ពីបទ**លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ សុំឲ្យតុលាការពិចារណារំលត់បណ្តឹងអាជ្ញាលើជនជាប់ចោទឈ្មោះ [redacted] **ហ្សឿងថាញ់** ដោយសារជនជាប់ចោទនេះបានស្លាប់បន្ទាប់ពីបញ្ជូនដល់មន្ទីរពេទ្យ ។

-មេធាវី [redacted] សន្និដ្ឋានថា: ក្តីខ្ញុំបានឆ្លើយសារភាពចំពោះអំពើដែលបានប្រព្រឹត្តអស់ហើយដូច្នេះ សុំឲ្យតុលាការបន្ធូរបន្ថយទោសផង ។

-ក្រោយពីបានស្តាប់ចម្លើយសារភាពជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សីសមត្ថកិច្ច

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៣១ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **២៤៦៩** "គ១" ដ.ដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញដែលបានបញ្ជូនជនជាប់ចោទ៖

ក-ឈ្មោះ[redacted] **វាំងតេវ** ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិវៀតណាម

ខ-ឈ្មោះ[redacted] **ហ្វឿងថាញ់** ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិវៀតណាម

ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-ឆ្លងតាមការសួរដេញដោលនាពេលសវនាការរួចឃើញថា កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ពិតជាមានអង្គហេតុដែលឈ្មោះ[redacted] **វាំងតេវ** និងឈ្មោះ[redacted] **ហ្វឿងថាញ់** បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃមួយគ្រឿងម៉ាក iPhone 13 Pro Max ពីជនរងគ្រោះឈ្មោះ[redacted] **ស្រីវិន** ដែលកំពុងធ្វើដំណើរលើផាស់អាប់ ប្រាកដមែន។

៣-តាមរបាយការណ៍សំយោគលេខ ០០៣/២២ រ.ប.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌបឹងកេងកង បានបញ្ជាក់ថា កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៤ និង ០៥ នាទី ជនសង្ស័យឈ្មោះ[redacted] **វាំងតេវ** និងឈ្មោះ[redacted] **ហ្វឿងថាញ់** ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ពិតប្រាកដមែន ។

៤-តាមចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿង មានលក្ខណៈស៊ីសង្វាក់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted] **វាំងតេវ** និងឈ្មោះ[redacted] **ហ្វឿងថាញ់** ពិតជាបានលួចទូរស័ព្ទដៃ ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ពិតមែន ។

៥-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វាំងតេវ** និងឈ្មោះ [redacted] **ហ្សឿងថាញ់** ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃអ្នកដទៃយកទៅលក់ ត្រូវបានច្បាប់កំណត់ថាជាបទល្មើស **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ហើយបញ្ញត្តិឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) **ឆ្នាំ** ទៅ ១០ (ដប់) **ឆ្នាំ** តាមមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វាំងតេវ** និងឈ្មោះ [redacted] **ហ្សឿងថាញ់** ធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដែលកំណត់ជាបទល្មើសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] **វាំងតេវ** និងឈ្មោះ [redacted] **ហ្សឿងថាញ់** ជានីតិជន និងជាជនដែលមាននីតិសម្បទាស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះ**អំពើ**របស់ខ្លួនដែលបានប្រព្រឹត្ត ។

៨-តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការ ដោយបានលើកឡើងពីភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **វាំងតេវ** ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** តាមមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ មានលក្ខណៈត្រឹមត្រូវតាម**អង្គ**ហេតុដែលបានកើតឡើង ។

៩-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កូនក្តីខ្ញុំបានឯកភាពតាមការចោទប្រកាន់របស់តំណាងអយ្យការ ដូចនេះសូមតុលាការធ្វើការបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំ ។

១០-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **វាំងតេវ** **អាយុ**ប្រុស និងឈ្មោះ [redacted] **ហ្សឿងថាញ់** **អាយុ**ប្រុស ពិតជាបានប្រព្រឹត្តបទល្មើស **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ**៦៣** ភូមិ**៤** សង្កាត់បឹងកេងកង**១** ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី**២៩** ខែមករា ឆ្នាំ**២០២២** បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

១១-តាមលិខិតមរណៈភាពលេខ ០០**១**៣**២**៣**៨**/**២២** ចុះថ្ងៃទី**១៣** ខែឧសភា ឆ្នាំ**២០២២** របស់មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត បញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] **ហ្សឿងថាញ់** បានស្លាប់នៅថ្ងៃទី**១៣** ខែឧសភា ឆ្នាំ**២០២២** ដែលជាមូលហេតុធ្វើឲ្យរលត់នៃបណ្តឹងអាជ្ញា ដូច្នេះគប្បីតុលាការពិចារណាឲ្យ**រួច**ខ្លួនពីបទចោទ តាមមាត្រា**៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១២-តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី**២៩** ខែមករា ឆ្នាំ**២០២២** របស់អធិការដ្ឋាននគរបាលខណ្ឌបឹងកេងកង មានម៉ូតូមួយគ្រឿងម៉ាក Honda សេ**១២៥** ពណ៌ខ្មៅ គ្មានស្លាកលេខ (ចាស់) ដែលជនជាប់ចោទប្រើប្រាស់ធ្វើជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូសតាមមាត្រា**៦២** និងមាត្រា**៦៣** នៃក្រមព្រហ្មទណ្ឌ ។

១៣-នាពេលសវនាការ និងដំណាក់កាលចៅក្រមស៊ើបសួរដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីវីន អវត្តមាន ដូច្នេះយោងតាមមាត្រា**១៣៨** និងមាត្រា**៣១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់ទុកថាមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងឡើយ ។

ហេតុផ្តេចផ្តើមសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] **វ៉ាងតេវ** ភេទប្រុស **អាយុ** ៤៧ឆ្នាំ ជនជាតិវៀតណាម **មុខរបរ ជាងដែក ទីកន្លែង** កំណើត[redacted] **ទីលំនៅ**មុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ភូមិត្នោតជ្រុំ **សង្កាត់**បឹងទំពុនទី២ **ខណ្ឌ** មានជ័យ **រាជធានី**ភ្នំពេញ **នៅលីវ ឪពុកឈ្មោះ** [redacted] **វ៉ាងសឹង្ហ** "រស់" **ម្តាយឈ្មោះ** [redacted] **អៀង** "ស្លាប់" ជានីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន ។

ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ ។

ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-ឱ្យឈ្មោះ [redacted] **ហ្សឹងថាញ់** ភេទប្រុស **អាយុ** ៤៨ឆ្នាំ ជនជាតិវៀតណាម **មុខរបរ ជាងឈើ ទីកន្លែង** កំណើតនៅ[redacted] **ទីលំនៅ**ពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួល ភូមិត្នោតជ្រុំ **សង្កាត់**បឹងទំពុន២ **ខណ្ឌ** មានជ័យ **រាជធានី**ភ្នំពេញ **នៅលីវ ឪពុកឈ្មោះ** [redacted] **ហ្សឹងវី** "រស់" **ម្តាយ មិនស្គាល់ឈ្មោះ** ជានីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការ-គ្មាន ។

រួចខ្លួន ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចមុខហាង Park Cafe ផ្លូវលេខ៦៣ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣-**វត្ថុតាងដែលត្រូវរឹបអូសមាន៖** ម៉ូតូមួយគ្រឿងម៉ាក Honda សេ១២៥ ពណ៌ខ្មៅ គ្មានស្លាកលេខ (ចាស់) ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៦កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]